00649405

F10

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 04 / 03 / 2011
ម៉ោង (Time/Heure) : 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Uch Arun

អង្គជំនុំជម្រះតុលាការកំពូល

Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 001/18-07-2007-ECCC/SC

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម **Motoo NOGUCHI**
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម **Agnieszka KLONOWIECKA MILART**
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម **Chandra Nihal Jayasinghe**
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

---

# ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ

---

<u>សហព្រះរាជអាជ្ញា៖</u>

ជា លាង
Andrew CAYLEY

<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១</u>

ទី ស្រីនណា
Karim KHAN
Alain WERNER
Brianne McGONIGLE

SUPREME COURT CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE LA COUR SUPRÊME

**ជនជាប់ចោទ៖**

កាំង ហ្កេកអ៊ាវ ហៅ "ឌុច"

**សហមេធាវីការពារក្តីជនជាប់ចោទ**

ការ សាវុត្ថ

កង ឫទ្ធារី

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម២**

គង់ ពិសី

ហុង គីមសួន

យុង ផានិត

Silke STUDZINSKY

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៣**

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

Martine JACQUIN
Annie DELAHAIE
Philippe CANONNE
Elizabeth RABESANDRATANA
Fabienne TRUSSES-NAPROUS
Christine MARTINEAU



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

00649407



**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(“អ.វ.ត.ក”):

**កត់សំគាល់ឃើញថា** សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេក អ៊ាវ *ហៅ* ឌុច (“សាលក្រមសាលាដំបូង”) ចេញថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០[1]។

**បានទទួល** បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូង របស់សហព្រះរាជអាជ្ញា ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ២ និង៣ (ជារួមហៅថា “ភាគីបណ្តឹងសាទុក្ខ” [2]។

---

[1] E188 (កែតម្រូវ)។

[2] បណ្តឹងសាទុក្ខបន្ទាន់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ចំពោះការសម្រេចដកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីចេញពីសាលក្រម, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០, F8; សារណាបន្ថែមរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ចំពោះសេចក្តីជូនដំណឹងអំពីគោលបំណង ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០, F12; បណ្តឹងសាទុក្ខរបស់សហមេធាវីតំណាង ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ប្រឆាំងទៅនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០, F9; បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ ឌុច, ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០, F10 (“សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា”); សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី(ក្រុម២)និងទឡ្ហីករណ៍បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម, ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០, E188/12; បណ្តឹងសាទុក្ខប្រឆាំងនឹងការបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសាលក្រម, សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២, ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០,F11; បណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមស្តីពីសំណងរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម២, ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០, F13; សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០, F14 (“សារណាបណ្តឹង សាទុក្ខ របស់ ជនជាប់ចោទ”); សំណើសុំកែតម្រូវលើសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១០, F14/Corr-1; សំណើសុំកែតម្រូវលើសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១១, F14/Corr-2; សារណាតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ទៅនឹងបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១០, ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១០, F14/2; និងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ “ឌុច” ប្រឆាំងនឹងសាលក្រមសាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០, F14/4។ ចម្លើយតប របស់សហព្រះរាជអាជ្ញា ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេក អ៊ាវ ហៅ ឌុច ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០, F14/4; ការឆ្លើយ តបរបស់សហមេធាវីការពារក្តីជនជាប់ចោទ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១, F14/4/2។

**រំលឹកឡើងវិញថា** ដោយអនុលោមតាមវិធាន១០៨(៣)នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៦) ក្រឡាបញ្ជីនៃអង្គជំនុំជម្រះ បានជូនដំណឹងដល់ភាគីទាំងអស់នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ ថាអង្គជំនុំជម្រះតុលាការកំពូល នឹងបើកសវនាការលើបណ្តឹងសាទុក្ខចាប់ពីថ្ងៃច័ន្ទ ទី២៨ ខែមីនា ឆ្នាំ២០១១ ដល់ថ្ងៃព្រហស្បតិ៍ ខែមីនា ឆ្នាំ២០១១ ហើយថា"កាលបរិច្ឆេទនៃសវនាការ ដែលរួមទាំងការកំណត់កាលបរិច្ឆេទ និងពេលវេលយ៉ាងច្បាស់លាស់ នឹងត្រូវជូនដំណឹងតាមពេលវេលាសមស្រប"។

**ពិចារណាឃើញថា** ការបញ្ជាក់នូវបញ្ហានានាខាងក្រោម មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គជំនុំជម្រះ ស្តីពីភាពអាចទទួលយកបាន ឬ អង្គសេចក្តីនៃបណ្តឹងសាទុក្ខនោះទេ។

## ហេតុដូច្នេះ

**បង្គាប់ថា** សវនាការបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០១/១៨/កក្កដា/២០០៧ អ.វ.ត.ក/អ.ជ.ត.ក ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូង នឹងចាប់ផ្តើមនៅថ្ងៃច័ន្ទ ទី២៨ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង៩:០០(ពេលវេលាក្នុងស្រុក)ក្នុងបន្ទប់សវនាការនៃអ.វ.ត.ក និងបញ្ចប់នៅប្រមាណម៉ោង ១៦:៣០ នាទី។

**បង្គាប់ថា** សវនាការបណ្តឹងសាទុក្ខ នឹងបន្តនៅថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១១ និងថ្ងៃពុធ ទី៣០ ខែមីនា ឆ្នាំ២០១១ ចាប់ផ្តើមនៅម៉ោង ៩:០០ និងបញ្ចប់នៅម៉ោងប្រមាណប្រហែល១៦:៣០នាទីរៀងរាល់ថ្ងៃ ហើយថា ប្រសិនបើការបន្ថែមម៉ោងចាំបាច់នោះ សវនាការបណ្តឹងសាទុក្ខ នឹងបន្តនៅ ថ្ងៃព្រហស្បតិ៍ ទី៣១ ខែមីនា ឆ្នាំ២០១១ ចាប់ផ្តើមនៅម៉ោង ៩:០០ និងបញ្ចប់នៅម៉ោង ១៦:៣០នាទី។

**អញ្ជើញ** ភាគីបណ្តឹងសាទុក្ខ ធ្វើការលើកឡើង ឬ ការអភិវឌ្ឍន៍បន្ថែមនូវសារណាផ្ទាល់មាត់នៅក្នុងសវនាការបណ្តឹងសាទុក្ខនូវបញ្ហានានាដូចខាងក្រោម ដោយមិនមានផលប៉ះពាល់ដល់បញ្ហាដែលអង្គជំនុំជម្រះ មានបំណងលើកឡើងនៅក្នុងសវនាការបណ្តឹងសាទុក្ខ:

<u>១.យុត្តាធិការបុគ្គល</u>

ក. សហមេធាវីការពារក្តីជនជាប់ចោទ សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ត្រូវបានអញ្ជើញឲ្យធ្វើការពិនិត្យ ថាតើពាក្យ"មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវបំផុត ក្នុងកិច្ចព្រមព្រៀង និងច្បាប់របស់អ.វ.ត.ក គឺ ជាលក្ខខណ្ឌយុត្តាធិការដែល

តម្រូវឲ្យមានការពិនិត្យឡើងវិញរបស់តុលាការ ឬ ជាការណែនាំពីឆន្ទានុសិទ្ធិរបស់ សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតដែលមិនតម្រូវឲ្យមាន ការពិនិត្យឡើងវិញរបស់តុលាការ ដែរឬទេ។

២.គោលការណ៍នីត្យានុកូលភាព

ក. សហមេធាវីការពារក្តីជនជាប់ចោទ ត្រូវបានអញ្ជើញឲ្យធ្វើការពន្យល់បន្ថែមនូវ ឯកសារយោងទៅលើគោលការណ៍នីត្យានុកូលភាពក្នុងសារណាបណ្តឹងសាទុក្ខ (ដូចជា ក្នុងកថាខណ្ឌ ១៤ ៦១-៦២ ៦៧ ៩៥ ១០០) និងការឆ្លើយតបរបស់ ជនជាប់ចោទ(ដូចជា ក្នុងកថាខណ្ឌ១២)។

៣.ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ក. សហមេធាវីការពារក្តីជនជាប់ចោទ ត្រូវបានអញ្ជើញឲ្យធ្វើការឆ្លើយតបទៅនឹង សារណាក្នុងកថាខណ្ឌ១៣២ដល់២០៩ក្នុងសារណាបណ្តឹងសាទុក្ខរបស់សហ ព្រះរាជអាជ្ញា។

ខ. សហព្រះរាជអាជ្ញា ត្រូវបានអញ្ជើញឲ្យធ្វើការពន្យល់ពីមូលដ្ឋានច្បាប់អន្តរជាតិស្តី ពីការផ្តន្ទាទោសត្រួតគ្នាក្នុងរឿងក្តីនេះ និងអានុភាពនៃការផ្តន្ទាទោសត្រួតគ្នាលើ ការកំណត់ទោស។

គ. សហមេធាវីការពារក្តីជនជាប់ចោទ និងសហព្រះរាជអាជ្ញា ត្រូវបានអញ្ជើញឲ្យ ធ្វើការពិនិត្យ ថាតើការរំលោភសេពសន្ថវៈ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់អន្តរជាតិស្ថិតនៅក្នុងកំឡុងយុត្តាធិការពេលវេលានៃអ.វ.ត.ក ដែរឬទេ។

ឃ. សហមេធាវីការពារក្តីជនជាប់ចោទ និងសហព្រះរាជអាជ្ញា ត្រូវបានអញ្ជើញឲ្យ ធ្វើការពិនិត្យថាតើ នៅក្នុងយុត្តាធិការពេលវេលារបស់អ.វ.ត.ក ច្បាប់ទំនៀម ទំលាប់អន្តរជាតិ តម្រូវឲ្យមានទំនាក់ទំនងរវាងអំពើជាមូលដ្ឋាននៃឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ និងជំលោះប្រដាប់អាវុធ ដែរឬទេ។

៤.ការកំណត់ទោស

ក. សហមេធាវីការពារក្តីជនជាប់ចោទ និងសហព្រះរាជអាជ្ញា ត្រូវ[illegible] ពិនិត្យបន្ថែម ថាតើ និងក្នុងកម្រិតណា ក្រមព្រហ្មទណ្ឌឆ្នាំ២[illegible]

រួមមានមាត្រា៦៦៨ អនុវត្តចំពោះការកំណត់នូវបណ្តឹងសាទុក្ខប្រឆាំងនឹងការកំណត់ទោសនោះ ដែរឬទេ។

<u>៥.ដើមបណ្តឹងរដ្ឋប្បវេណី</u>

ក. ក្រុមដើមបណ្តឹងរដ្ឋប្បវេណី ដែលស្នើសុំដាក់ភស្តុតាងបន្ថែម ត្រូវបានអញ្ជើញឱ្យធ្វើការពន្យល់ពីមូលហេតុ ដែលភស្តុតាងនេះ មិនអាចរកបាននៅពេលជំនុំជម្រះ។

ខ. ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ត្រូវបានអញ្ជើញឱ្យធ្វើការបញ្ជាក់ថា "ទម្រង់នៃសំណង" ដែលខ្លួនបាននឹងកំពុងស្នើសុំពីអង្គជំនុំជម្រះតុលាការកំពូល គឺ "ការទទួលស្គាល់នូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំបួននាក់" ប៉ុណ្ណោះទេ[3]។

**ភ្ជាប់ជាមួយ** នូវតារាងកំណត់កាលបរិច្ឆេទស្តីពីសវនាការបណ្តឹងសាទុក្ខក្នុងឧបសម្ព័ន្ធ ១។

**កត់សំគាល់ឃើញថា** អនុលោមតាមវិធាន១០៩(៦)នៃវិធានផ្ទៃក្នុង លើកលែងមានការអនុញ្ញាតពីអង្គជំនុំជម្រះ ភាគីមិនអាចលើកឡើងបញ្ហាអង្គហេតុ ឬ អង្គច្បាប់ណាមួយដែលមិនបានបញ្ជាក់នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួនក្នុងពេលសវនាការឡើយ។

**រំលឹកថា** ភាគីបណ្តឹងសាទុក្ខ មិនអាចគ្រាន់តែលើកឡើងវិញក្នុងការដេញដោលផ្ទាល់មាត់នូវអ្វីដែលបានរៀបរាប់ក្នុងសារណាជាលាយលក្ខណ៍អក្សររបស់ខ្លួនឡើយ ប៉ុន្តែត្រូវពន្យល់បន្ថែមឱ្យបានលម្អិតនូវចំនុចនានាដែលទាក់ទិនបំផុតទៅនឹងបណ្តឹងសាទុក្ខរបស់ខ្លួនរៀងៗខ្លួន។

**និងរំលឹកថា** ដោយកន្លែងមានកំណត់ក្នុងបន្ទប់សវនាការសំរាប់ដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គល និងមេធាវីរបស់ខ្លួន **បង្គាប់ថា** មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ២ និង៣ ត្រូវជូនដំណឹងមកក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលជាលាយលក្ខណ៍អក្សរ ត្រឹមថ្ងៃសុក្រ ទី១១ ខែមីនា ឆ្នាំ២០១១ នូវចំនួនដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គលណាខ្លះ ដែលមានវត្តមានក្នុងបន្ទប់សវនាការក្នុងអំឡុងពេលសវនាការបណ្តឹងសាទុក្ខ។

---

[3] សារណាបន្ថែមរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ចំពោះសេចក្តីជូនដំណឹងអំពីគោលបំណង [illegible] ឆ្នាំ២០១០, F12, កថាខណ្ឌ៥។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១

ប្រធានអង្គជំនុំជម្រះតុលាការកំពូល

គង់ ស្រ៊ឹម